THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF OPERATIONS**
440 North Broad Street
Philadelphia, PA 19130

**Reginald McNeil**
Chief Operating Officer

ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០២២

ជូនចំពោះ មាតាបិតា និងក្រុមគ្រួសារទាំងអស់របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

ក្រសួងសាធារណៈសុខាភិបាលនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា បង្ហាញជាបន្តថា ចំនួនអ្នកឆ្លងរោគ ខូវីដ-១៩ នៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យ៉ា នៅតែមានកម្រិតទាបដដែល។ ការថយចុះនៃការឆ្លងរោគនេះ បានបណ្តាលឱ្យគ្មានការបិទសាលាទាល់តែសោះក្នុងរយៈពេលប៉ុន្មានសប្តាហ៍កន្លងមកនេះ ដែលជាសញ្ញានៃការផ្លាស់ប្តូរស្វាគមន៍ឆ្ពោះទៅរកភាពប្រក្រតីឡើងវិញនៅក្នុងសហគមន៍សាលារបស់យើង។ **ដោយសារតែការរីកចម្រើនដ៏ល្អនេះ ក្រសួងផ្នែកម្ហូបអាហារនឹងបិទទីតាំងចែកចាយអាហារដែលនៅសល់ចំនួន ១២ បន្ទាប់ពីថ្ងៃនេះ ថ្ងៃសុក្រ ទី ១៨ ខែ មីនា ឆ្នាំ ២០២២។**

ប្រសិនបើមានការកើនឡើងនៃការឆ្លងរោគ ខូវីដ ហើយសាលារបស់ក្រសួងត្រូវបានណែនាំឲ្យបង្រៀនសិស្សតាមបណ្តាញអ៊ិនធ័រណិតវិញ ក្រសួងផ្នែកម្ហូបអាហារនឹងចែកចាយ អាហារពេលព្រឹក និងអាហារថ្ងៃត្រង់ នៅសាលាជារៀងរាល់ថ្ងៃ ចាប់ផ្តើមនៅថ្ងៃបន្ទាប់ ពីម៉ោង ៩ ដល់ ១១ ព្រឹក។ អាហារនឹងមានចែកចាយជារៀងរាល់ថ្ងៃ រហូតដល់សាលាចាប់ផ្តើមការបង្ហាត់បង្រៀនក្នុងថ្នាក់ផ្ទាល់តាមធម្មតាវិញ។ ក្រុមគ្រួសារណាដែលបន្តត្រូវការជំនួយម្ហូបអាហារប្រចាំថ្ងៃគួរមើលគេហទំព័រ www.phila.gov/food ដើម្បីស្វែងរកព័ត៌មានអំពីទីតាំងម្ហូបអាហារដែលដំណើរការដោយទីក្រុងហ្វីឡាដែលហ្វ្យ៉ា។

យើងខ្ញុំមានអំណរគុណយ៉ាងជ្រាលជ្រៅដែលអាចផ្តល់សេវាកម្មនេះដល់សហគមន៍ក្នុងទីក្រុងហ្វីឡាដែលហ្វ្យ៉ា ហើយនឹងបន្តខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាពដើម្បីគាំទ្រសិស្សរបស់យើង និងបំពេញតម្រូវការអាហារូបត្ថម្ភរបស់ពួកគេ។

ដោយសេចក្តីស្មោះស្ម័គ្រ

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា
ក្រសួងផ្នែកប្រតិបត្តិការ